# សេរីភាពនៃការបញ្ចេញមតិ



## ក. មុខងារនៃសេរីភាពជាមូលដ្ឋាននេះ :

តំរូវការចាំបាច់ជាមូលដ្ឋានមួយក្នុងចំណោមតំរូវការនានារបស់មនុស្ស គឺដើម្បីរស់នៅជាក្រុម ។ ការរស់នៅជាមួយគ្នាជាមួយមនុស្សឯទៀត ធ្វើឱ្យមានការចាំបាច់ដើម្បីស្វែងយល់អំពីពួកគេ **ប្រាស្រ័យទាក់ទងជាមួយពួកគេ** និងដើម្បីជជែកពិភាក្សាជាមួយពួកគេនូវបញ្ហារួមនិងដំណោះស្រាយនៃបញ្ហាទាំងនោះ ។

តំរូវការចាំបាច់ជាមូលដ្ឋានមួយទៀតរបស់មនុស្សគឺដើម្បីចូលរួមក្នុងដំណើរការនៃការសំរេចចិត្ត ។ដោយសារតែមនុស្សមានតំលៃដូចគ្នានិងមនុស្សដ៏ទៃទៀត មតិរបស់បុគ្គលម្នាក់ក៏មានតំលៃដូចមតិអ្នកដ៏ទៃដែរ។ គោលគំនិតនៃសង្គមពហុនិយមគឺអាស្រ័យលើគំនិតបែបនេះ ។ វាធ្វើអោយសង្គមមានភាពរស់រវើក ចំរុះពណ៌និងកាន់តែរឹងមាំនៅពេលសមាជិករបស់ខ្លួនទាំងអស់អាចរួមចំណែកផ្តល់គំនិត និងទស្សនៈ ។ ការស្តាប់លើមតិ**ទាំងអស់**បង្កើនឱ្យមានឱកាសរកឃើញដំណោះស្រាយត្រឹមត្រូវសំរាប់បញ្ហានានានៃសង្គម ។ វាក៏បង្កើនឱកាសធ្វើការសំរេចចិត្តនានាឱ្យបានត្រឹមត្រូវផងដែរ ។

ការពឹងផ្អែកលើទស្សនៈតែមួយជាសញ្ញានៃការខ្វះគតិបណ្ឌិត ពីព្រោះបទពិសោធន៏បង្រៀនថា"ភ្នែកបួនមើលឃើញច្រើនជាងភ្នែកពីរ" ។ ការទប់ស្កាត់ទស្សនៈអ្នកដ៏ទៃ ក៏ជាសញ្ញានៃភាពអន់ខ្សោយ និងភ័យខ្លាច ពីព្រោះវាបង្ហាញថា អ្នកគាបសង្កត់គេមិនអាចព្ទ និងអត់ធនចំពោះមតិដទៃទៀត និងមិនមានម្ចាស់ការខ្លួនឯង គ្រប់គ្រាន់ដើម្បីចូលរួមក្នុងការប្រជែងមតិដោយសេរី ។

នៅក្នុងរបបប្រជាធិបតេយ្យសេរីពហុបក្សដែលមានប្រជាជនរាប់លាននាក់ (ឧទាហរណ៏ៈ ប្រជាជនកម្ពុជាចំនួន១៤លាន) ការប្រាស្រ័យទាក់ទងដោយផ្ទាល់ និងការដោះដូរគំនិតយោបល់នានាជាមួយគ្នាទៅវិញទៅមកមិនអាចធ្វើទៅបានឡើយ ។ ដូច្នេះប្រជាជនចូលរួមដោយផ្ទេរអំណាចរបស់គេក្នុងការសំរេចចិត្ត (តាមរយៈការបោះឆ្នោត) ទៅអោយតំណាងរបស់ខ្លួន ។ តំណាងទាំងនេះ (ឧទាហរណ៏ៈ ក្រុមប្រឹក្សាឃុំសង្កាត់, សមាជិកសភា និងព្រឹទ្ធសភា, តំណាងនិស្សិតជាប់ឆ្នោត ) ធ្វើការតាក់តែងច្បាប់ ។ រដ្ឋាភិបាលជាអ្នកអនុវត្តន៏ច្បាប់នានា ចំណែកឯតុលាការជាអ្នកត្រួតពិនិត្យការអនុវត្តន៏ច្បាប់ ។ ពួកគេទាំងអស់ជាអ្នកទទួលខុសត្រូវចំពោះប្រជាជន ។

ដូច្នេះហើយ **ពត៌មានផ្សព្វផ្សាយដោយសេរី** រវាងតួអង្គទាំងនេះមានសារៈសំខាន់ណាស់សំរាប់សង្គមប្រជាធិបតេយ្យមួយ ៖

១. ដោយម្យ៉ាង ប្រជាពលរដ្ឋត្រូវតែ**ទទួលបានពត៌មានដោយសេរី**អំពីសង្គមរបស់គេ និងរាល់ប្រធានបទ និងតួអង្គដែលពាក់ព័ន្ធ (ឧទាហរណ៍ៈ កម្មវិធីរបស់គណៈបក្សនយោបាយ, ពង្រាងច្បាប់, អំពីគោលនយោបាយរដ្ឋាភិបាល, កិច្ចប្រជុំ, ការកាត់សេចក្តី និងដំណើរការគ្រប់បែប) ។ ពុំនោះសោធទេ ប្រជាពលរដ្ឋមិនអាចធ្វើការជ្រើសរើសតំណាងរបស់ខ្លួនដោយសេរីបានទេ មិនអាចចូលរួមក្នុងដំណើរការតាក់តែងច្បាប់តាមរយៈការពិភាក្សា មិនអាចត្រួតពិនិត្យអំណាចនីតិប្រតិបត្តិរបស់រដ្ឋាភិបាលខ្លួន និងមិនមានឥទ្ធិពលលើការអនុវត្តន៍ច្បាប់ដោយតុលាការដែលសំរេចសេចក្តីក្នុងនាមប្រជាពលរដ្ឋ ។

២. នៅលើផ្នែកម្ខាងទៀត ប្រជាពលរដ្ឋត្រូវមានលទ្ធភាព**បញ្ចេញមតិយោបល់របស់ខ្លួន**អំពីរឿងរ៉ាវទាំងអស់នេះ ផ្តល់យោបល់ ពិភាក្សាជាមួយអ្នកដ៏ទៃទៀត និងចូលរួមផ្តល់យោបល់របស់ខ្លួន អំពីដំណោះស្រាយបញ្ហាសង្គមនៅក្នុងដំណើរការនៃការសំរេចចិត្ត ។

**សង្គម ៖** **ស្ថាប័ន ៖**




**សេរីភាពនៃការបញ្ចេញមតិមានសារៈសំខាន់សំរាប់លទ្ធិប្រជាធិបតេយ្យ** ដែលមានមូលដ្ឋានលើការជជែកវែកញែកជាសាធារណៈ ការសំរេចចិត្តជាចំហរ និងការដោះដូរដោយសេរីអំពីគំនិតយោបល់និងពតិមាន ។ សេរីភាពនេះមានសារៈសំខាន់សំរាប់ការអភិវឌ្ឍន៍ចំណេះដឹង និងការយោគយល់គ្នាក្នុងចំណោមប្រជាពលរដ្ឋ ។ វាជំរុញឱ្យមានការអត់ឱនគ្នា និងកិច្ចសហប្រតិបត្តិការ ។ សេរីភាពក្នុងការទទួលបានពតិមានធានាឱ្យមាន **តម្លាភាព** និង**ការទទួលខុសត្រូវ**របស់ស្ថាប័នប្រជាធិបតេយ្យ ជាពិសេសរបស់រដ្ឋាភិបាល[២១] ។ បើគ្មានសេរីភាព នៃការប្រាស្រ័យទាក់ទងនេះ រដ្ឋនឹងថ្លង់ ចំណែកប្រជាជនក៏ថ្លង់ដែរ ។

[២១] សូមមើល**គោលការណ៍ Johannesburg** (www.hrni.org/~lhennebe/files/instruments/HRNi_EN_470rtf) និង**សេចក្តីប្រកាសអន្តរអាមេរិកាំង**ស្តីពីគោលការណ៍នានានៃសេរីភាពក្នុងការបញ្ចេញមតិ (www.hrni.org/~lhennebe/files/instruments/HRNi_EN_1076.rtf). សេចក្តីប្រកាសទាំងពីរនេះមិនមែនជាអនុសញ្ញាដែលចងភ្ជាប់នោះទេ ប៉ុន្តែបានផ្តល់ឧបករណ៍ដ៏មានប្រយោជន៍សំរាប់ការបកស្រាយលំអិតចំពោះសេរីភាពនៃការបញ្ចេញមតិ ។

"ការផ្សព្វផ្សាយជាសាធារណៈជាឱសថសំរាប់ព្យាបាលជំងឺសង្គម ចំណែកឯពន្លឺព្រះអាទិត្យជាថ្នាំរំងាប់មេរោគដ៏ស័ក្តិសិទ្ធិ"[២២] ។

"ចំណេះដឹង នឹងដឹកនាំភាពល្ងង់ខ្លៅជារៀងរហូត ។ ហើយមនុស្សដែលតាំងខ្លួនជាអ្នកដឹកនាំ ត្រូវមានអំណាចដែលបានមកពីចំណេះដឹង"[២៣] ។

## ខ. សមាសធាតុនៃសេរីភាពបញ្ចេញមតិ :

ដោយហេតុថា សេរីភាពនេះមានសារសំខាន់ និងជាមូលដ្ឋាន **វាមិនមែនជាការធ្វើសម្បទានដោយរដ្ឋទេ ប៉ុន្តែ** ជាសិទ្ធិជាមូលដ្ឋាននិង**សិទ្ធិមិនអាចលក់ ឬផ្ទេរបានឡើយ**របស់មនុស្សម្នាក់ៗ ។ សិទ្ធិនេះស្របច្បាប់ធានាដោយបញ្ញត្តិពីរ :

> មាត្រា៤១ CC:
>
> ពលរដ្ឋខ្មែរគ្រប់រូបមានសេរីភាពចំពោះការបញ្ចេញមតិ សារពត៌មាន ការបោះពុម្ពផ្សាយ និង ការជួបជុំ ។

ជាពិស្តារថែមទៀតនោះ ICCPR ពិពណ៌នាអំពីសមាសធាតុនានានៃសេរីភាពក្នុងការបញ្ចេញមតិ និងផ្តល់ឱ្យវានូវកិច្ចគាំពារដ៏ទូលាយមួយចំពោះការបញ្ចេញមតិគ្រប់ប្រភេទ :

> មាត្រា១៩ ICCPR :
>
> ១. ជនគ្រប់រូបមានសិទ្ធិប្រកាន់យកមតិយោបល់ដោយគ្មានការជ្រៀតជ្រែក ។
>
> ២. ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញយោបល់ ។ សិទ្ធិនេះត្រូវរាប់ទាំងសេរីភាពក្នុងការស្វែងរកពត៌មាន ទទួលពត៌មាន និងផ្សព្វផ្សាយពត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែនឡើយ ទាំងតាមផ្ទាល់មាត់ក្តី, តាមការសរសេរ ឬបោះពុម្ពក្តី, តាមទំរង់សិល្បៈក្តី ឬតាមរយៈចរន្តផ្សាយ ពត៌មានដទៃៗទៀតក្តី ។

ក្នុងអត្ថន័យដ៏ទូលំលាយ សេរីភាពនៃការបញ្ចេញមតិនេះ រាប់បញ្ចូលមិនត្រឹមតែសេរីភាពក្នុងការចែកចាយពត៌មាន និងគំនិតផ្សេងៗគ្រប់បែប" ប៉ុណ្ណោះទេ ប៉ុន្តែរួមទាំងសេរីភាព "ក្នុងការស្វែងរក" និង"ទទួល"ពត៌មានទាំងនោះ "ដោយមិនគិតពីព្រំដែន" និងតាមប្រព័ន្ធផ្សព្វផ្សាយអ្វីក៏ដោយ "ដោយផ្ទាល់មាត់ ជាលាយល័ក្ខ អក្សរ ឬដោយការបោះពុម្ពផ្សាយក្នុងទំរង់សិល្បៈ ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយដ៏ទៃទៀតណាមួយដែលគេពេញចិត្ត"[២៤] ។ នេះមានន័យថា :

---

[២២] តុលាការជាន់ខ្ពស់អាមេរិច ចៅក្រម Louis.D.Brandeis

[២៣] James Madison, " បិតានៃរដ្ឋធម្មនុញ្ញអាមេរិក "

[២៤] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីអធិប្បាយទូទៅលើមាត្រា១៩ ICCPR -២៩.៦.១៩៨៣-(ចុច "Treaties" លើគេហទំព័រ www.unchr.ch )

- សេរីភាពនៃការបញ្ចេញមតិ សំដៅមិនត្រឹមតែលើ **ការពិត ទិន្នន័យ និងពត៌មាន**ប៉ុណ្ណោះទេ ប៉ុន្តែរួមទាំង **គំនិតយោបល់ ទស្សនៈផងដែរ** ។

  សំគាល់: គំនិត និងទស្សនៈនានាដែលប្រឆាំង ឬទិតៀន អំពីនយោបាយ ឬរដ្ឋាភិបាល បង្ហាញយ៉ាងច្បាស់ផងដែរនៅក្នុងទំហំនៃការការពារនូវសិទ្ធិជាចំបងរបស់សេរីភាពក្នុងការបញ្ចេញមតិ ។

- ជាមូលដ្ឋាន សេរីភាពនេះ រួមបញ្ចូលផងដែរនូវ**សេរីភាពនៃពត៌មាន**ដែលមានន័យថា ជា**ការទទួលបានពត៌មានដោយសេរី**[២៥] ពីព្រោះពត៌មានអំពីគំនិត និងការពិតគឺជាមូលដ្ឋានគ្រឹះសំរាប់ការបង្កើតគំនិត និងទស្សនៈ ។

  ឧទាហរណ៍: ដើម្បីធានាឱ្យមានសិទ្ធិជាមូលដ្ឋានគ្រឹះនៃសេរីភាពសារពត៌មាន ការកាត់ក្តីនានារបស់តុលាការ ឬសម័យប្រជុំនានារបស់រដ្ឋសភាក្នុងប្រទេសកម្ពុជាទាំងអស់ ត្រូវបើកទូលាយចំពោះសាធារណជន ។ សិទ្ធិទទួលពត៌មានដោយសេរី នឹងទទួលការប៉ះពាល់នៅពេលអ្នកសារពត៌មាននានា មិនត្រូវបានអនុញ្ញាតឱ្យចូល និងរាយការណ៍អំពីអង្គប្រជុំនានារបស់សាលាក្រុងភ្នំពេញ ឬ នៅពេលប្រធានរដ្ឋបាលនៃសភាជាតិចេញបទបញ្ជាថា គេត្រូវជំរាបជូនដំណឹងដល់គាត់ជាមុនអំពីការមកជួបនិមួយៗរបស់អ្នកកាសែតជាមួយនឹងសមាជិកសភា នៅក្នុងអគាររដ្ឋសភា ។ សិទ្ធិសេរីភាពនៃការទទួលពត៌មានន័យថា ប្រយោជន៏សាធារណៈក្នុងការទទួលបានពត៌មានមានអាទិភាពខ្ពស់ និងរាល់ឯកសារនានារបស់រដ្ឋាភិបាលត្រូវតែបង្ហាញ លើកលែងតែ រដ្ឋាភិបាលអាចបញ្ជាក់ថាឯកសារនោះអាចបំពានសន្តិសុខជាតិ[២៦] ។

- ការបញ្ចេញមតិ និងការទទួលបានពត៌មានតាមរយៈ**ប្រព័ន្ធឃោសនាអេឡិចត្រូនិច ដូចជា វិទ្យុ ទូរទស្សន៍ ផ្កាយរណប ខ្សែកាប ឬអ៊ីនធើណិត** ក៏ត្រូវគ្របដណ្តប់ដោយសេរីភាពនៃការបញ្ចេញមតិផងដែរ ។ សេរីភាពក្នុងការបញ្ចេញមតិ គឺមិនមានព្រំដែនដល់ការនិយាយស្តី ឬ ដល់សារពត៌មានសេរីនោះទេ ។

  ឧទាហរណ៍: ប្រទេសចិនរំលោភសិទ្ធិនេះដោយប្រើប្រាស់បច្ចេកទេសទប់ស្កាត់មិនឱ្យបើកគេហទំព័រ សិទ្ធិមនុស្សមួយចំនួននៅក្នុងប្រព័ន្ធអ៊ីនធើណិត ។

- **លំហូរពត៌មានដោយសេរី** គឺមិនត្រូវបានហាមឃាត់ចំពោះដែនដីក្នុងប្រទេសមួយប៉ុណ្ណោះទេ ប៉ុន្តែរួមទាំង **ការដោះដូរគ្នានៃពត៌មាន និងគំនិតនានាជាមួយនិងប្រទេសដ៏ទៃទៀត** ។

  ឧទាហរណ៍: ការគំរាមដកហូតអាជ្ញាប័ណ្ណពីស្ថានីយ៍វិទ្យុមួយក្នុងប្រទេសកម្ពុជា ដែលចង់ផ្សាយកម្មវិធីបរទេសនានានៃវិទ្យុប៊ីប៊ីស៊ី ឬវិទ្យុអាស៊ីសេរី នឹងប៉ះពាល់ផងដែរចំពោះសិទ្ធិនៃសេរីភាពក្នុងការបញ្ចេញមតិ ពីព្រោះវាអាចកាត់ផ្តាច់សាធារណជនកម្ពុជាឱ្យឆ្ងាយពីពត៌មានខាងក្រៅ ។

## គ. គ្រោះថ្នាក់នានាសំរាប់សិទ្ធិបញ្ចេញមតិដោយសេរី :

មនុស្សជាច្រើន និងរដ្ឋាភិបាលនានា និងបុគ្គលឯកជនផ្សេងៗ មិនយល់ពិតប្រាកដអំពីតំលៃដ៏ធំធេងនៃលំហូរពត៌មានដោយសេរីសំរាប់សង្គមឡើយ ។ ពួកគេចាត់ទុកសេរីភាពបញ្ចេញមតិជាឧបសគ្គ ឬជាការគំរាមកំហែងមួយដល់នយោបាយ និងមធ្យោបាយធ្វើជំនួញរបស់ខ្លួន ។ ពួកគេមិនចង់បានដំណើរការនៃការពិភាក្សាមួយដែលមានលក្ខណៈរិះគន់ បើកចំហរ និងមានតម្លាភាព ដែលបង្កើនការទទួលខុសត្រូវរបស់ពួកគេឡើយ ។ ប៉ុន្តែ ពេញចិត្តឱ្យ

[២៥] មើល http://usinfo.state.gov/procucts/pubs/archive/freedom/freedom/freedom6.htm

[២៦] សូមមើលគោលការណ៍ ១១ -១៩ នៃគោលការណ៍ Johannesburg (សូមមើលលេខយោង២១)

ប្រជាជនធ្វើថ្លង់ និង ធ្វើត ។ ឬពួកគេមិនយល់ពីអត្ថន័យនៃពហុនិយម និងគិតថា មានតែទស្សនៈរបស់ខ្លួនប៉ុណ្ណោះដែលសំខាន់ ។

ហេតុដូច្នេះហើយ ពួកគេព្យាយាមទប់ស្កាត់សេរីភាពបញ្ចេញមតិដោយមធ្យោបាយផ្សេងៗ ដូចជា:

- វិធានការអាក្រក់បំផុត គឺ**ការសំលាប់** ឬ **ការចាប់ខ្លួនតាមអំពើចិត្ត** ឬ **ការគំរាមគំហែងដោយផ្ទាល់ដល់**អ្នកកាសែតនានា ឬមនុស្សដ៏ទៃទៀតដែលព្យាយាមប្រាស្រ័យទាក់ទងគ្នាដោយសេរី ។
- ឬច្បាប់នានាត្រូវបានប្រើសំរាប់ទប់ស្កាត់សេរីភាពបញ្ចេញមតិ ។
  ឧទាហរណ៍: ច្បាប់សារពត៌មានដែល ចេញបទបញ្ជាអោយមាន**ការត្រួតពិនិត្យពត៌មានជាមុន ឬច្បាប់ស្ដីពីការបរិហារកេរ្តិ៍ / បង្ខូចកេរ្តិ៍ដោយសរសេរ** ត្រូវបានប្រើដើម្បីប្តឹងប្រឆាំងនិងអ្នកកាសែតនានា ឬប្រព័ន្ធផ្សព្វផ្សាយពត៌មានដែលជួនកាល បណ្តាលឱ្យបែកបាក់មូលដ្ឋានសេដ្ឋកិច្ចរបស់ពួកគេ ។ ជាចុងក្រោយ **ច្បាប់ព្រហ្មទណ្ឌ**នានា ត្រូវបានប្រើដើម្បីដាក់ទោសការប្រើសិទ្ធិបញ្ចេញមតិ ដោយសេរី និងដាក់ពន្ធនាគារអ្នករិះគន់ទិតៀនទាំងឡាយ ។
- កង្វះខាតទាំងស្រុងនៃ**ច្បាប់ផ្សព្វផ្សាយពត៌មាន**[២៧] ដែលមានលក្ខណៈច្បាស់លាស់ ឬ**ច្បាប់ទាំងឡាយស្ដីពីការទទួលបានពត៌មានដោយសេរី** ឬភាពមិនច្បាស់លាស់ ឬការហាមឃាត់នៃការរៀបចំច្បាប់ទាំងនោះត្រូវបានគេរំលោភបំពានដោយសារការដាក់ចេញនូវការគ្រប់គ្រងហួសហេតុ ឬការហាមឃាត់នានាលើលំហូរពត៌មានដោយសេរី ។

មានស្ថាប័នជាច្រើនពាសពេញពិភពលោក ដែលបានប្រកាសជាសាធារណៈអំពីគ្រោះថ្នាក់ចំពោះសិទ្ធិនៃសេរីភាពបញ្ចេញមតិ និងព្យាយាមប្រយុទ្ធជាមួយគ្រោះថ្នាក់ទាំងនេះ ។

ឧទាហរណ៍ :

- **អ្នករាយការណ៍ពិសេសរបស់គណៈកម្មការទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ** បោះផ្សាយរបាយការណ៍ជារៀងរាល់ឆ្នាំស្ដីពីស្ថានភាពនៅលើពិភពលោកនៃសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់[២៨] ។
- **ស្ថាប័នឈ្មោះសេរីភាពនៃការដោះដូរមតិជាអន្តរជាតិ (IFEX)** បោះពុម្ពពត៌មាន និងសេចក្តីរាយការណ៍ជាច្រើនអំពីសិទ្ធិនេះ រួមទាំងរបាយការណ៍មួយចំនួនអំពីស្ថានភាពនៅប្រទេសកម្ពុជា[២៩] ។
- **វិទ្យាស្ថានសារពត៌មានអន្តរជាតិ (IPI)**[៣០] និង **តំណាងសេរីភាពនៃការបញ្ចេញមតិ OSCE**[៣១] ក៏ដូចជា**អ្នកយកពត៌មានគ្មានព្រំដែន (RSF)**[៣២] ក៏រាយការណ៍អំពីបញ្ហានេះដែរ ។
- **ស្ថាប័នឈ្មោះយុទ្ធនាការជាសកលសំរាប់សេរីភាពក្នុងការបញ្ចេញមតិ** បោះពុម្ពសេចក្តីបរិយាយគួរឱ្យចាប់អារម្មណ៍ជាច្រើន និងពត៌មានទាក់ទង និងមាត្រា១៩ នៃ ICCPR[៣៣] ។

[២៧] តើគេបង្កើតប្រព័ន្ធផ្សព្វផ្សាយពត៌មានដោយសេរីយ៉ាងដូចម្តេច? មើល http://usinfo.state.gov/procucts/pubs/ardhive/freedom/freedom1.htm
[២៨] សូមមើលរបាយការណ៍សំរាប់ឆ្នាំ២០០២ (www.hri.ca/fortherecord2002/vol1/opinionchr.htm )
[២៩] សូមមើលគេហទំព័រ : www.ifex.org និងទំនាក់ទំនងរបស់វាជាមួយរបាយការណ៍ស្ដីពីស្ថានភាពកម្ពុជា www.ifex.org/en/content/view/full/146/
[៣០] សូមមើលគេហទំព័រ : www.freemedia.at/
[៣១] សូមមើលគេហទំព័រ : www.osce.org/fom/
[៣២] សូមមើលគេហទំព័រ : www.rsf.org
[៣៣] សូមមើលគេហទំព័រ : www.article19.org

## ឃ. ការដាក់កំរិតទៅលើសិទ្ធិបញ្ចេញមតិ:

អត្ថបទជាច្រើនស្តីពីមាត្រាសិទ្ធិមនុស្សនៅក្នុងរដ្ឋធម្មនុញ្ញ ឬ ក្នុងអនុសញ្ញាអន្តរជាតិចែងយ៉ាងជាក់លាក់ថា សិទ្ធិជាមូលដ្ឋាននេះអាចត្រូវបានគេដាក់ដែនកំណត់ ហើយកំរិតដោយច្បាប់សំរាប់គោលបំណងជាក់លាក់ ជាពិសេសដើម្បីការពារនូវសេរីភាពរបស់អ្នកដទៃ ។

មាត្រា១៩ ICCPR:

ការអនុវត្តសិទ្ធិដែលបានចែងក្នុងវគ្គទី២ នៃមាត្រានេះ ត្រូវជួបប្រទះនឹងការទទួលខុសត្រូវ និងកាតព្វកិច្ចខ្លះៗ ។ ជួនកាលវាអាចជួបប្រទះនឹងការកំរិតល័ក្ខខ័ណ្ឌដែលច្បាប់បានបញ្ញត្តិជាចាំបាច់ដើម្បី:
(ក) គោរពសិទ្ធិ និង កិត្តិនាមអ្នកដទៃ
(ខ) ការពារសន្តិសុខជាតិ របៀបរៀបរយ សាធារណៈ ព្រមទាំងសុខមាលភាពនិងសីលធម៌ និងសីលធម៌សាធារណៈ ។

រដ្ឋធម្មនុញ្ញកម្ពុជាមាត្រា ៤១:

ពលរដ្ឋខ្មែរទាំងអស់នឹងមានសេរីភាពខាងការបញ្ចេញមតិ លើសារពត៌មាន ការបោះពុម្ពផ្សាយ និងការប្រជុំគ្នា ។ គ្មាននរណាម្នាក់នឹងប្រើសិទ្ធិនេះដើម្បីរំលោភដល់សិទ្ធិអ្នកដទៃ ជះឥទ្ធិពលដល់ប្រពៃណីល្អៗរបស់សង្គម រំលោភដល់ច្បាប់សាធារណៈ និង បទបញ្ជា ហើយព្រមទាំងសន្តិសុខជាតិទៀតផង ។

ច្បាប់មួយដែលដាក់នូវកំរិតបែបនេះលើសិទ្ធិជាមូលដ្ឋានគឺមានធម្មនុញ្ញភាព និងស្របទៅតាមបទដ្ឋានសិទ្ធិមនុស្ស លុះត្រាតែច្បាប់នោះអនុវត្តតាមគោលបំណងពិសេសនេះ ហើយមិនដាក់នូវ**កំរិតមិនចាំបាច់ (វិសមាមាត្រ)** ណាមួយលើសិទ្ធិនេះ ។ ក្នុងគ្រប់ករណីទាំងអស់ ដែនកំណត់ដែលកំរិតដោយច្បាប់មិនត្រូវមានលក្ខណៈ**ធ្ងន់ធ្ងរហួសហេតុ ដើម្បីហាមប្រាមលើការប្រើសិទ្ធិនេះទាំងស្រុងនេះទេ** ។ ច្បាប់ក៏ត្រូវតែកំណត់ឱ្យបានច្បាស់នូវករណីទាំងឡាយសំរាប់ការដាក់កំរិត ។ ជាទូទៅច្បាប់មួយដែលផ្តល់អំណាចដល់រដ្ឋអំណាចក្នុងការដាក់កំហិតលើសិទ្ធិមួយនោះ មិនស្របទៅតាមតំរូវការនៃការកំរិតជាធម្មនុញ្ញនៃសិទ្ធិមួយទេ ។ វាត្រូវតែផ្តល់ការបង្ហាញយ៉ាងជាក់លាក់ថាពេលណាដែលការកំរិតនេះអាចត្រូវបានគេដាក់បាន ។ វាត្រូវតែមានភាពចំហ មានភាពត្រឹមត្រូវ ល្អិតល្អន់ និងដោយជាក់លាក់ដើម្បីធ្វើឱ្យជនម្នាក់ៗអាចមើលឃើញជាមុនថា សកម្មភាពជាក់លាក់ណាមួយស្របច្បាប់ ឬមិនស្របនោះ[៣៤] ។

**ការប្រុងប្រយ័ត្ន:**

ខចែងទាំងនេះបើកទ្វារមួយសំរាប់ការដាក់កំរិត ។ ចំណុចនេះតែងតែបង្កើតនូវការគ្រោះថ្នាក់មួយថាមន្ត្រីរដ្ឋាភិបាល ឬអ្នកបង្កើតច្បាប់ ឬតុលាការអនុលោមទៅតាមខចែងទាំងនេះដើម្បីបង្ហាញនូវភាពស្របច្បាប់លើការដាក់កំរិតនានាដែលមិនត្រូវបានគ្របដណ្តប់ដោយគោលបំណងពិសេស ឬដែលមិនចាំបាច់ ឬមិនមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ ។

ដូច្នេះរាល់ការដាក់កំរិតទាំងអស់គួរតែត្រូវបានគេត្រួតពិនិត្យដូចខាងក្រោម:

[៣៤] សូមមើលគោលការណ៍លេខ ១.១.ក នៃសេចក្តីប្រកាសរបស់ Johannesburg (សូមមើលលេខយោងទី២១)

- តើវាជាការកំរិតមួយដោយច្បាប់ (ដោយផ្អែកលើច្បាប់) ឬ?
- តើខ្លឹមសារច្បាប់មានភាពជាក់លាក់គ្រប់គ្រាន់ទេ ឬ ក៏ទូលំទូលាយពេក?
- តើការដាក់កំរិតនេះដើរតាមគោលបំណងមួយដែលត្រូវបានគេបញ្ជាក់ក្នុងមាត្រាសិទ្ធិមនុស្សដែរឬទេ?
- តើការដាក់កំរិតនេះមានលក្ខណៈសមាមាត្រ (តើវាចាំបាច់ឬទេ? តើវាធ្ងន់ធ្ងរពេកដែលមិនទុកឱ្យមាននូវសិទ្ធិសូម្បីតែបន្តិច ប៉ុន្តែបែរជាដាក់នូវកំរិតទាំងស្រុងឬ?)

**អាជ្ញាធរទទួលបន្ទុកភស្តុតាងដែលបង្ហាញថា ការដាក់កំហិតមួយបំពេញនូវលក្ខណៈវិនិច្ឆ័យទាំងនេះហើយ ប្រសិនណា ពួកគេមានបំណងចង់បង្កើតនូវការដាក់កំហិតបែបនោះ!**

យោលទៅលើមាត្រា១៩ ICCPR និង៤១ CC សិទ្ធិខាងសេរីភាពបញ្ចេញមតិអាចត្រូវបានគេកំរិតត្រឹមតែសំរាប់គោលបំណងជាក់លាក់ទាំងស្រុងមួយចំនួនប៉ុណ្ណោះ ។ ហេតុផលគឺថា ទោះបីជាសេរីភាពខាងការបញ្ចេញមតិជាមូលដ្ឋានមិនទាក់ទងទៅនឹងអំពើហឹង្សាហើយមានតំលៃធំធេងក៏ដោយ ក៏ការអនុវត្តន៍របស់វារួមបញ្ចូលក្នុងករណីជាក់លាក់មួយចំនួនតូចនូវគ្រោះថ្នាក់មួយដល់អ្នកដទៃដែរ ដូចជា ការបំពានខាងពាក្យសំដីអាចធ្វើឱ្យមានការឈឺចាប់ដូចកាំបិតមុតស្រួចដែរ ហើយវាបង្ខូចនូវសេចក្តីថ្លៃថ្នូររបស់មនុស្សបាន ។ ការប្រាប់អ្វីមិនពិតអំពីអ្នកណាម្នាក់ជាសាធារណៈក៏មានឥទ្ធិពលដូចគ្នាដែរ ហើយពាក្យសំដីអាចត្រូវបានគេប្រើដើម្បីបង្កើតនូវការស្អប់ ដែលនាំទៅរកភាពមានអំពើហិង្សាដាក់គ្នាទៀតផង ។ ការប្រើសេរីភាពខាងការបញ្ចេញមតិនេះមិនត្រូវបានគេការពារទេ ។

**គោលបំណងជាក់លាក់នានាដែលហាមឃាត់លើការប្រើប្រាស់សេរីភាពខាងការបញ្ចេញមតិគឺជា:**

**ការការពារដល់:**

- **សិទ្ធិរបស់អ្នកដទៃ**

ឧទាហរណ៍: ដើម្បីការពារនូវកិត្តិយសរបស់អ្នកដទៃចំពោះការបំពានខាងពាក្យសំដី (សិទ្ធិរក្សាកិត្តិយស មាត្រា៣៨ II CC[៣៥]) ។ ជាការពិតណាស់នេះមានន័យថាគ្មានការការពារទប់ទល់នឹងការរិះគន់ តែការការពារលើវិធីជាក់លាក់មួយចំនួននៃការបញ្ចេញមតិជាវិជ្ជមានចំពោះនរណាម្នាក់ តាមរយៈការជ្រើសរើសនូវពាក្យសំដីខ្លះ (មិនល្អ មិនគួរសម កំណាច) ដែលរំលោភដល់សេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួនរបស់គេ ។ ដូច្នេះអ្នក នយោបាយអាចត្រូវបានគេហៅថា "ជនពុករលួយ" បើមានភស្តុតាងពីបញ្ហានោះ តែគាត់មិនអាចត្រូវបានគេហៅថា "សត្វឆ្កែកន្ទុយខ្សៀន" (Corrupt dog) នោះទេ ។

គោលបំណងស្របច្បាប់មួយលើការកំរិតនៃសេរីភាពខាងការ បញ្ចេញមតិក៏នឹងរំលោភទៅលើទំរង់ទាំងអស់នៃការប្រើសំដីរើសអើងដែលញុះញង់ឱ្យមានអំពើហិង្សា សង្គ្រាម ការប្រកាន់ពូជសាសន៍ និងបទឧក្រិដ្ឋនានាដល់ជនជាតិភាគតិច (សូមមើលមាត្រា៦ និង១១ នៃច្បាប់សារពត៌មាន, មាត្រា៦១ I នៃច្បាប់ព្រហ្មទណ្ឌ ឬមាត្រា២០ I II ICCPR) ។ សេរីភាពខាងការបញ្ចេញមតិ (ឧទាហរណ៍ បង្ហាញពីរឿងភាពយន្តតាមរោងកុន) អាចត្រូវបានគេកំរិតផងដែរ ដើម្បីការពារយុវវ័យមិនអោយប្រឈមមុខនឹងការរៀបរាប់ និងបង្ហាញឱ្យឃើញនូវបញ្ហាផ្លូវភេទ និងបទឧក្រិដ្ឋ ពីព្រោះវានឹងធ្វើអោយខូចដល់សីលធម៌សិក្សារបស់គេបាន (សូមមើលមាត្រា៤៨ II CC[៣៦]) ។

- **ប្រពៃណីល្អៗរបស់សង្គម**

[៣៥] "ច្បាប់នឹងការពារដល់ជីវិត កិត្តិយស និង សេចក្តីថ្លៃថ្នូររបស់ពលរដ្ឋ" ។

[៣៦] "រដ្ឋនឹងការពារកុមារគេចផុតពីទង្វើរទាំងឡាយណាដែលធ្វើអោយខូចដល់ឱកាសសិក្សា សុខភាព និង សុខមាលភាពរបស់ពួកគេ" ។

គោលបំណងនេះ ត្រូវតែបានគេធ្វើការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ ពីព្រោះវាមានន័យទូលំទូលាយ ហេតុដូច្នេះវាអាចត្រូវបានគេបំពានដើម្បីគាបសង្កត់ទៅលើទស្សនៈប្រឆាំង និងរិះគន់ ។ អ្នកណាកំណត់ន័យនូវអ្វីដែលជាប្រពៃណី"ល្អ"របស់សង្គម[៣៧]? វាអាស្រ័យទៅលើសង្គមខ្លួនឯងតែប៉ុណ្ណោះ ដើម្បីកំណត់ន័យរបស់ប្រពៃណីទាំងនេះ ។ អ្នកបង្កើតច្បាប់ដែលជាអ្នកតំណាងឱ្យសង្គមបានកំណត់និយមន័យរបស់ស័ព្ទនេះ នៅក្នុងអត្ថបទច្បាប់ (មាត្រា១៤ នៃច្បាប់សារពត៌មាន) ។

ឧទាហរណ៍: "ប្រពៃណីល្អរបស់សង្គមខ្មែរ" អាចជា ការគោរពអ្នកដែលមានវ័យចំណាស់ជាង (មាត្រា៤៧ II CC[៣៨]) ឬការគោរពព្រះមហាក្សត្រកម្ពុជា "បុគ្គលដែលមិនអាចបំពានបាន" (មាត្រា៧ III CC[៣៩]) ។ ជាការពិតណាស់វាមិនអាចត្រូវបានគេហៅថា "ប្រពៃណីល្អទេ" ដែលការទិតៀនជាសាធារណៈត្រូវបានគេយល់ថាជាភាពអសីលធម៌ទាំងស្រុងទៅវិញនោះ ។ ការបកស្រាយបែបនេះអាចតំរង់ទិសចំចំណុចសំខាន់នៃលំហូរពត៌មាន និងការដោះដូរនូវគំនិត និងទស្សនៈទៅវិញទៅមក ។

- **ច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ**

ច្បាប់ទាំងឡាយណាដែលមិនមានគោលបំណងទប់ស្កាត់នូវទស្សនៈពិសេសមួយ តែបែរជាមានគោល-បំណង ផ្សេងទៀតនោះ វាអាចក៏រិតនូវសេរីភាពខាងការបញ្ចេញមតិ ។

ឧទាហរណ៍: ច្បាប់ចរាចរមានគោលដៅដើម្បីការពារឱ្យមានការធ្វើដំណើរដោយស្រួល មិនឱ្យមានគ្រោះថ្នាក់ចរាចរ ។ ច្បាប់បែបនេះ ឧទាហរណ៍ អាចហាមប្រាមមិនឱ្យដាក់នូវរូបឃោសនានយោបាយ (ឬរូបផ្សេងទៀតដែលសំដែងនូវទស្សនៈរបស់អ្នកណាម្នាក់) នៅកណ្តាលផ្លូវ (សូមមើលមាត្រា៥២ច្បាប់ចរាចរផ្លូវគោក) ។ ទោះបីជាវាក៏រិតនូវសេរីភាពខាងការបញ្ចេញមតិ ក៏វាក៏រិតបានតែមធ្យោបាយពិសេសនៃការសំដែងទស្សនៈតែប៉ុណ្ណោះ ។ តែវាមិនក៏រិតត្រឹមតែទស្សនៈពិសេសប៉ុណ្ណោះទេ ថែមទាំងគ្រប់ទស្សនៈទាំងអស់ដែលត្រូវបានគេសំដែងនៅក្នុងមធ្យោយដ៏គ្រោះថ្នាក់នេះទៀតផង ។

ឧទាហរណ៍មួយ ចំពោះច្បាប់ដែលមានគោលបំណងចំពោះទស្សនៈពិសេសមួយអាចជាច្បាប់ដែលហាមឃាត់លើការសំដែង និងការបោះពុម្ពផ្សាយនៃទស្សនៈកុម្មុយនីស និងបញ្ជាឱ្យមានការដកហូតយកនូវសៀវភៅទាំងឡាយណាដែលនិពន្ធដោយអ្នកនិពន្ធកុម្មុយនីស្ត ។

ឧទាហរណ៍មួយផ្សេងទៀត អាចជាច្បាប់របស់ប្រទេសម៉ាឡេស៊ីដែលហាមប្រាមនូវការបោះពុម្ពផ្សាយនូវគម្ពីគ្រីស្តសាសនា ដោយផ្អែកទៅលើការសន្និដ្ឋានថា វាអាចបណ្តាលឱ្យមានចលាចលសាធារណៈក្នុងប្រទេសគ្របដណ្តប់ទៅដោយសាសនាមូស្លីមនេះ ។

- **សន្តិសុខជាតិ**

សន្តិសុខជាតិមិនមែនមានន័យថារាល់សន្តិសុខជាប្រយោជន៏របស់រដ្ឋាភិបាលទេ ។ បើមិនដូច្នេះទេ រដ្ឋាភិបាលអាចហាមឃាត់រាល់ការបញ្ចេញមតិទាំងអស់ដោយគ្រាន់តែនិយាយថា វាប៉ះពាល់នឹងផលប្រយោជន៏របស់រដ្ឋាភិបាល ។

[៣៧] រដ្ឋាភិបាលឬ? សូមមើលមាត្រា៥២ CC: "រដ្ឋាភិបាលកម្ពុជា...នឹងរក្សានូវប្រពៃណីជាតិល្អរបស់ប្រទេស" ។ ប្រយ័ត្ន: "រក្សា"មិនមានន័យថា "ការកំណត់និយមន័យទេ" ។

[៣៨] "កូនចៅមានកាតព្វកិច្ចថែរទាំឪពុកម្តាយចាស់ជរារបស់គេ តាមប្រពៃណីរបស់ខ្មែរ" ។

[៣៩] "ព្រះមហាក្សត្រមិនត្រូវបានប៉ះពាល់ឡើយ" ។

ដូច្នេះសន្តិសុខជាតិត្រូវតែធ្វើការកំណត់ន័យអោយកាន់តែល្អិតល្អន់ថែមទៀត ។ សន្តិសុខជាតិ មានន័យ ថា ការគ្រោះថ្នាក់ដល់ជីវិត និងសន្តិសុខរបស់ប្រជាពលរដ្ឋទាំងមូល ឧទាហរណ៍ ជីវិតរបស់ជាតិទាំងមូលស្ថិតក្នុងភាពគ្រោះថ្នាក់ ពីព្រោះតែការវាយប្រហារយោធាពីប្រទេសផ្សេងទៀត ឬ ដោយមានការញុះញង់ឱ្យមានអំពើហិង្សាទំលាក់រដ្ឋាភិបាលកាន់អំណាចសព្វថ្ងៃ ។

ឧទាហរណ៍: ច្បាប់អាចហាមប្រាមមិនលាតត្រដាងនូវការសំងាត់ផ្នែកយោធាបាន ឬដាក់ទណ្ឌកម្មលើការបញ្ចេញមតិយោបល់ដែលមានទំនោរញុះញង់ឱ្យមាននូវអំពើហិង្សាឡើង ។

តែវាមិនស្ថិតក្នុង**គោលបំណងការពារនូវសន្តិសុខជាតិ**នោះទេ ការដែលហាមប្រាមដល់:

- ការទិតៀនអហឹង្សាចំពោះរដ្ឋាភិបាល
- ការអំពាវនាវឱ្យមានការផ្លាស់ប្តូររដ្ឋាភិបាលដោយសន្តិវិធី
- ការផ្សព្វផ្សាយពីការប្រព្រឹត្តិខុសរបស់រដ្ឋាភិបាល
- ការបរិហារនូវពតិមានស្តីពីដំណើរការមិនល្អរបស់ស្ថាប័នសាធារណះ
- ការអំពាវនាវឱ្យមានការធ្វើកុប្បកម្ម ឬការបះបោរឧស្សាហកម្ម
- ការលើកកំពស់ដល់មនោគមវិជ្ជាពិសេសមួយ[៤០] ។

## **សូមចងចាំក្នុងចិត្តជានិច្ចៈ**

ទោះបីជាឯកសារខាងមាត្រាស្តីពីសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជា ឬក្នុងICCPR ផ្តល់នូវគោលបំណងនីតិវិធីសំរាប់ការដាក់កំរិតមួយ មិនមែនការដាក់កំរិតទាំងអស់ត្រូវបានគេអនុញ្ញាតនោះទេ មានតែការដាក់កំរិតដោយសមាមាត្រដែលកំរិតនូវសិទ្ធិតាមមធ្យោបាយត្រជាក់ដែលអាចធ្វើបានប៉ុណ្ណោះដែលគេអនុញ្ញាត ។




វិធានការត្រជាក់ដើម្បីកំរិតនូវសេរីភាពបញ្ចេញមតិ នឹងគ្រាន់តែចេញនូវការព្រមានទៅអ្នកណាដែលមិនគោរពច្បាប់សារពតិមាន ហើយបោះពុម្ពផ្សាយ ជាឧទាហរណ៍នូវអត្ថបទដែលប្រើប្រាស់ពាក្យប្រមាទ ។ បើពតិមាន

[៤០] សូមមើលគោលការណ៍ ១.១, ១.៣, ២, ៦ និង ៧ នៃគោលការណ៍របស់ Johannesburg (សូមមើលលេខយោងទី២១)

មិនពិតត្រូវបានគេចេញផ្សាយ វិធានការធ្ងន់ជាងនេះ គឺនឹងបញ្ជាឱ្យធ្វើការកែតំរូវឡើងវិញនូវអត្ថបទផ្សាយនោះ ។ ក្នុងករណីបរិហារ ឬបង្ខូចកេរ្តិ៍ឈ្មោះ ការពិន័យអាចត្រូវបានគេធ្វើឡើង ឬតុលាការស៊ីវិលអាចធ្វើការសំរេចដែលតំរូវឱ្យមានការបង់ជាប្រាក់ (ឧទាហរណ៍មាត្រា១០ ច្បាប់សារពត៌មាន) ។ ទោះបីជាក្នុងករណីច្បាស់លាស់នៃការបង្ខូចកេរ្តិ៍ឈ្មោះ ការផាកពិន័យ ឬ ការបញ្ជាឱ្យបង់ នឹងមិនត្រូវស្មើនឹងចំនួនលុយដែលធ្វើឱ្យអ្នកសារពត៌មាន ឬកាសែត ឬក៏ស្ថានីយ៍វិទ្យុបិទទ្វារ ពីព្រោះវានឹងជាការកំរិតមិនសមាមាត្រមួយ ។ ការដាក់ពន្ធធនាគារចំពោះអ្នកកាសែត ឬមនុស្សម្នាក់ៗដោយផ្អែកលើការរំលោភលើខចែងច្បាប់ឧក្រិដ្ឋ និងជាវិធានការ ដាក់កំហិតខ្លាំងបំផុត ។ ការកំរិតយ៉ាងខ្លាំងស្តីពីសេរីភាពបញ្ចេញមតិនេះ មិនត្រូវប្រើប្រាស់ក្នុងករណីបង្ខូច កេរ្តិ៍ឈ្មោះ ឬ ការបរិហារ តែនឹងត្រូវបានប្រើតែក្នុងករណីទាក់ទងនឹងការប្រកាន់ជាតិសាសន៍ ឬការរើសអើងខាង ពាក្យសំដី ឬការអំពាវនាវឱ្យមានអំពើហិង្សា[៤១] ។ សូមធ្វើការពិចារណាលើករណីនេះ ផ្តល់អនុសាសន៍ និងពិនិត្យថាតើការដាក់ទាំងអស់នៅក្នុងមាត្រា៥៩ ដល់ ៦៣ នៃក្រមព្រហ្មទណ្ឌអន្តរកាល មានលក្ខណៈសមាមាត្រដែរឬទេ ។

[៤១] សូមមើលអនុសាសន៍របស់អ្នករាយការណ៍ពិសេសលើសេរីភាពក្នុងការបញ្ចេញមតិ និងគោលការណ៍ទី១០ នៃសេចក្តីប្រកាសអន្តរអាមេរិកាំង (សូមមើលលេខយោងទី២១)

# សេរីភាពក្នុងការបញ្ចេញមតិ

## មុខងារ →

ការទំនាក់ទំនង

ការចូលរួម

តម្លាភាព

ការទទួលខុសត្រូវ

## ធាតុផ្សំ →

អង្គហេតុ/យោបល់

លំហូរដោយសេរីនៃព័ត៌មាន

ក្នុង/ក្រៅប្រទេស

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានគ្រប់ប្រភេទ

- អ៊ីនធើណិត
- ពាក្យ/សំដី
- វិទ្យុ/ទូរទស្សន៍
- ខ្សែកាប/សាថឡាយ
- ការផ្សព្វផ្សាយដោយបោះពុម្ព

ព័ត៌មាន

- ស្វែងរក
- ទទួល
- ផ្ញើរ
- ទទួលបានព័ត៌មាន

## គ្រោះថ្នាក់ →

ការវាយប្រហារ
ការគំរាមកំហែង
ការសំលាប់ ដោយផ្ទាល់

របបសាព័ត៌មាន

- ការត្រួតពិនិត្យជាមុន
- ពិន័យលើការខូចខាត

ក្រមព្រហ្មទណ្ឌ

- ការដាក់ពន្ធធនាគារចំពោះបទល្មើសដែលប្រព្រឹត្តដោយអនីតិជន

នីតិរដ្ឋប្បវេណី

- បណ្តឹងពីបទបរិហារកេរ្តិ៍/ការខូចខាត

ការផ្តោតអារម្មណ៍លើពាណិជ្ជកម្មនៃប្រព័ន្ធផ្សព្វផ្សាយឯកជន

- នៅក្នុងដៃពាណិជ្ជករមួយផ្នែកផ្សព្វផ្សាយ

## ការដាក់កំហិត →

ចំនួនកំណត់នៃគោលបំណងនៃការដាក់កំហិត

សិទ្ធិរបស់អ្នកដទៃ

- កេរ្តិ៍ឈ្មោះ
- ការពិត/បរិហារកេរ្តិ៍

សីលធម៌យុវជន

- ប្រពៃណីល្អ

សណ្តាប់ធ្នាប់សាធារណៈ

- របៀបបង្ហាញគំនិតមិនត្រូវបំពានសណ្តាប់ធ្នាប់សាធារណៈទេ

សន្តិសុខជាតិ

- មានតែករណីការវាយប្រហារ/ការគំរាមកំហែងផ្នែកយោធាប៉ុណ្ណោះ

## ភាពសមាមាត្រ

ការព្រមាន

ពិន័យ
(មិនខ្ពស់ដល់ថ្នាក់ធ្វើឱ្យក្រុមហ៊ុនកាសែតបិទទ្វារនោះទេ)

ពន្ធធនាគារ:

ក្នុងករណីពាក្យសំដីដែលមានលក្ខណៈស្អប់ខ្ពើម និងហិង្សា

ក្តីបរិហារកេរ្តិ៍

សំណងមានចំនួនច្រើនដែលអាចធ្វើឱ្យមានការខូចខាតដល់ជនល្មើស

## ? សំនួរសិក្សាទី៩

**ក.** ចូររៀបរាប់បទបញ្ញត្តិច្បាប់ជាតិ និងអន្តរជាតិ (ចំនួនមាត្រា) ដែលការពារដល់សិទ្ធិក្នុងការបញ្ចេញមតិដោយសេរី!

**ខ.** សំរាប់មូលហេតុអ្វីខ្លះដែលគេអាចធ្វើការដាក់កំហិតដល់សេរីភាពក្នុងការបញ្ចេញមតិ? ចូររៀបរាប់មូលហេតុទាំងអស់នោះដែលមានចែងនៅក្នុងអត្ថបទច្បាប់ជាតិ និងអន្តរជាតិ ។

## ? សំនួរសិក្សាទី១០

អត្ថបទនៅក្នុងកាសែតតូចមួយ ដាក់ឈ្មោះអ្នកនយោបាយថាជា "ឆ្កែកន្ទុយខ្មៀន - Corrupt dog" ។ អ្នកនយោបាយរូបនោះបានដាក់ពាក្យប្តឹងកាសែតនោះតាមផ្លូវតុលាការរដ្ឋប្បវេណី ។ តុលាការរដ្ឋប្បវេណីបង្ខំឱ្យខាងកាសែតបង់ពិន័យចំនួន ៥.០០០.០០០៛ (មាត្រា១០នៃច្បាប់ស្តីពីសារពតិមាន) ។ កាសែតតូចនោះគ្មានលទ្ធភាពបង់ប្រាក់ពិន័យនេះទេ ហើយត្រូវបិទហាងកាសែតរបស់ខ្លួនទៀត ។

**ក.** តើការដាក់កំហិតសេរីភាពសារពតិមានស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញដែរឬទេ?

**ខ.** តើប្រតិកម្មអ្វីខ្លះរបស់តុលាការដែលសមាមាត្រនឹងករណីនេះ?

**គ.** ចូរពិនិត្យមើលការដាក់កំហិតទៅលើសេរីភាពសារពតិមានក្នុងមាត្រា១២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីសារពតិមាន ។ តើពាក្យពីរខុសគ្នា "សន្តិសុខជាតិ" និង "ស្ថេរភាពនយោបាយ" ស្របទៅនឹងរដ្ឋធម្មនុញ្ញកម្ពុជាដែរទេ?

## ? សំនួរសិក្សាទី១១

**ក.** សូមអានច្បាប់ស្តីពីសារពតិមាន។
តើច្បាប់ស្តីពីសារពតិមានអនុញ្ញាតឱ្យមានការត្រួតពិនិត្យជាមុនដែរឬទេ?

**ខ.** មាត្រា២០ នៃច្បាប់ស្តីពីសារពតិមានយោងទៅលើការបំពានក្រមព្រហ្មទណ្ឌដែលធ្វើទៅបាន ។ សូមធ្វើការរៀបរាប់ដោយប្រុងប្រយ័ត្ន!

**គ. សំណុំរឿង**

សមាជិកទាំងឡាយរបស់ "សមាគមគ្រូបង្រៀន" ពិភាក្សាអំពីប្រាក់បៀវត្ស និង លទ្ធភាពទៅរកការធ្វើកូដកម្ម ។ អភិបាលខេត្តអះអាងថា ការពិភាក្សានេះមិនស្របច្បាប់ទេ ព្រោះវាជាការគំរាមកំហែងដល់សន្តិសុខជាតិ និងថាប្រាក់បៀវត្សខ្ពស់អាចបង្កឱ្យមានការខូចខាតដល់ថវិកាជាតិ។ បន្ទាប់អភិបាលខេត្តបានហាមឃាត់កិច្ចពិភាក្សានោះ។
តើការហាមឃាត់នេះស្របច្បាប់ ឬ មិនស្របច្បាប់?